**អនុក្រឹត្យលេខ ៧៤ អនក្រ.បក**

**ស្តីពីសៀវភៅគ្រួសារ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម- ០១៩៦-០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- បានការអនុម័តរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៧

**សំរេច**

**មាត្រា ១** .- ត្រូវបានបង្កើតសៀវភៅគ្រួសារ ដូចមានគំរូចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២** .- សៀវភៅគ្រួសារ ជាសៀវភៅប្រើប្រាស់សំរាប់បញ្ជាក់ ពីសមាជិកគ្រួសារ ដែលមានសញ្ជាតិខ្មែរ និង ពីចំណងញាតិភាពនៃគ្រួសារនីមួយៗរួមមានសហព័ទ្ធ និងកូនបង្កើត ឬ កូនសុំ ។

**មាត្រា ៣** .- គ្រួសារនីមួយៗ ដែលជាប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលរស់នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានសៀវភៅគ្រួសារមួយ ។

ជនបរទេស គ្មានសិទ្ធិ កាន់កាប់ ប្រើប្រាស់ សៀវភៅគ្រួសារនេះទេ ។

**មាត្រា ៤** .- ការគ្រប់គ្រង និង ការចុះឈ្មោះសៀវភៅគ្រួសារ ជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ៥** .- បែបបទនៃការចុះឈ្មោះ ក្នុងសៀវភៅគ្រួសារ ត្រូវកំណត់ដោយប្រកាសក្រសួងមហាផ្ទៃ ។

**មាត្រា ៦** .–ជនណាដែលគ្មានសញ្ជាតិខ្មែរហើយក្លែងបន្លំតាមរូបភាពណាក៏ដោយ ដើម្បីកាន់កាប់សៀវភៅគ្រួសារ ឬ អាជ្ញាធរមានសមត្ថកិច្ចណា ដែលអនុវត្តការកិច្ចនេះ ផ្ទុយពីបទបញ្ញត្តិ នៃ អនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា ៧** .–បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨** .–សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

**អ៊ុង ហួត** **ហ៊ុន សែន**

*****

## អនុក្រឹត្យ លេខ ២១១ អនក្រ.តត

## ស្តីពីការ

## តម្លើងឋានន្តរសក្តិ និង តែងតាំងផ្លាស់ប្តូរមុខងារ នាយទាហាន

* * * *

## រាជរដ្ឋាភិបាល

–បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃ រាជរដ្ឋាភិបាលកម្ពុជា

–បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា .